វាយសារឡើងវិញឯកសារបកប្រែជាផ្លូវការ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អន្តរក្រសួងសុខាភិបាល**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

លេខៈ ៣៤៨ ប្រកសហវ

# ប្រកាសអន្តរក្រសួង
# ស្តីពីការសាកល្បងឱ្យសេវាសុខាភិបាលអនុវត្តការពិនិត្យ
# និងព្យាបាលជំងឺដោយយកកម្រៃខ្លះពីអ្នកជំងឺ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ នរោត្តម សីហនុ វរ្ម័ន ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ នរោត្តម សីហនុ វរ្ម័ន លេខ ១០៩៤-៩៣ ន.ស.រ.ក.ត ចុះថ្ងៃទី ២៤-១០-៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា។
- បានឃើញសេចក្តីជូនដំណឹងលេខ ១២៩១ ស.ជ.ណ.អ.វ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៤ របស់ទីស្តីការគណៈ រដ្ឋមន្ត្រី ស្តីពីការឯកភាពជាគោលការណ៍ ឱ្យមន្ទីរពេទ្យរដ្ឋ ថ្នាក់កណ្តាល ថ្នាក់ខេត្ត-ក្រុង និងថ្នាក់ស្រុក រៀបចំផ្នែកពិនិត្យ និងព្យាបាលជំងឺយកកម្រៃពីអ្នកជំងឺខ្លះ។

## សំរេច

### ប្រការ ១.-

ត្រូវបានអនុញ្ញាតឱ្យផ្នែកសេវាសុខាភិបាលរៀបចំបង្កើតការពិនិត្យ និងព្យាបាលជំងឺយកកម្រៃខ្លះពីអ្នកជំងឺ តាមវិធីសាកល្បង តាមមន្ទីរពេទ្យ ថ្នាក់កណ្តាល មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព។

### ប្រការ ២.-

សេវាដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមគោលនយោបាយសុខាភិបាល ដោយត្រូវយកចិត្តទុកដាក់ថែទាំអ្នកជំងឺ គោរពសីលធម៌វិជ្ជាជីវៈ ក្នុងស្មារតីមនុស្សធម៌ទូលំទូលាយ រក្សាបាននូវគុណភាពសេវា និងមិនយកកម្រៃពីអ្នក ជំងឺក្រីក្រ។

**ប្រការ ៣.-**

ការកំណត់កំរិតកម្រៃដែលត្រូវយកពីអ្នកជំងឺ អាស្រ័យដោយគណៈកម្មការមួយ ដែលមានអំណាចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំណាចក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន អំណាចទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានសាមុីអង្គភាព រៀបចំ ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល សម្រាប់អង្គភាពនៅថ្នាក់កណ្តាល។ ចំពោះអង្គភាពសុខាភិបាល ខេត្ត-ក្រុង ស្រុក និងមណ្ឌលសុខភាព អាស្រ័យដោយគណៈកម្មការមួយដែលមានតំណាងអាជ្ញាធរនៅតាមខេត្ត-ក្រុង ស្រុក ឃុំ តំណាងសហគមន៍ តំណាងមន្ទីរហិរញ្ញវត្ថុ ខេត្ត-ក្រុង តំណាងមន្ទីរសង្គមកិច្ចការងារនិងអតីតយុទ្ធជន ខេត្ត-ក្រុង និងប្រធានសាមុីអង្គភាពរៀបចំដោយមន្ទីរសុខាភិបាល ខេត្ត-ក្រុង។

**ប្រការ ៤.-**

ថវិកាដែលប្រមូលបានពីអ្នកជំងឺ ត្រូវគ្រប់គ្រង និងចាត់ចែងប្រើប្រាស់ ដោយគណៈកម្មការមួយដែលបានតែងតាំង តាមប្រការ ៣ ខាងលើ តាមលក្ខខ័ណ្ឌដូចខាងក្រោមនេះ:

- ៤០ ភាគរយ សម្រាប់ជំនួយបង្កើនគុណភាពសេវាកម្ម
- ៤០ ភាគរយ សម្រាប់ចំណាយឧបត្ថម្ភមន្ត្រីរាជការ និយោជិក។
- ៤០ ភាគរយ សម្រាប់បង់ចូលថវិកាជាតិ។

**ប្រការ ៥.-**

ដើម្បីអោយមានតម្លាភាពក្នុងការប្រើប្រាស់ប្រាក់ចំណូលនេះ គណៈកម្មការហិរញ្ញប្បទាន ត្រូវធ្វើរបាយការណ៍មួយ ជូនក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានជាប្រចាំរៀងរាល់ត្រីមាស។

**ប្រការ ៦.-**

ចាត់ទុកជាមោឃៈ រាល់សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ។

**ប្រការ ៧.-**

ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រការ ៨.-**

នាយខុទ្ទកាល័យក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុង ប្រធានមន្ទីរពេទ្យថ្នាក់កណ្តាលត្រូវអនុវត្ត តាមប្រកាសនេះ ដោយអនុលោមតាមខ្លឹមសារនៃបញ្ញត្តិ ស្តីអំពីហិរញ្ញប្បទានសុខាភិបាល លេខ ២៩៦ សកគន ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ដែលមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងសង្គមកិច្ច ការងារនិងអតីត យុទ្ធជន និងតំណាងទីស្តីការគណៈរដ្ឋមន្ត្រី។

ភ្នំពេញ ថ្ងៃទី ០៥ ខែ ០៦ ឆ្នាំ ១៩៩៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**គាត ឈន់** **វេជ្ជ. ឈា ថាំង**

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- នាយកដ្ឋានសុខាភិបាល
- គ្រប់អង្គភាពសុខាភិបាលថ្នាក់កណ្តាល ខេត្ត-ក្រុង និងស្រុក
- ឯកសារ